# ថ្ងៃទីប្រាំពីរ សេចក្តីសម្រាក

**មេរៀនទី២ ការប្រកាសព្រះគ្រីស្ទពីគម្ពីរសញ្ញាចាស់ លោកុប្បត្តិ ២-៣**

## គោលបំណងដ៏ធំ

តើអ្នកមានគោលបំណងនៅក្នុងជីវិតដែរឬទេ? សេចក្តីផ្តើមនៃព្រះគម្ពីរគឺសំខាន់ពីព្រោះវាបានបង្រៀនយើងថា ព្រះជាម្ចាស់បានបង្កើតគ្រប់អ្វីទាំងអស់ ប៉ុន្តែលើសពីនេះទៅទៀត លោកុប្បត្តិ១-២ បានសំដែងគោលបំណងរបស់ព្រះជាម្ចាស់ក្នុងការបង្កើត។

លោកុប្បត្តិ ១:១-២:៣ បញ្ជាក់ប្រាប់អំពីថ្ងៃទាំងប្រាំពីរ ហើយថ្ងៃទីប្រាំពីរខុសប្លែកពីថ្ងៃទីមួយដល់ទីប្រាំមួយ។ សូមអានលោកុប្បត្តិ ២:១-៣ ហើយព្យាយាមស្វែងរកភាពខុសគ្នារវាងថ្ងៃទីប្រាំពីរនិងថ្ងៃទីមួយដល់ថ្ងៃទីប្រាំមួយ។

ថ្ងៃទីប្រាំពីរខុសប្លែកពីថ្ងៃទីមួយដល់ទីប្រាំមួយយ៉ាងហោចណាស់បួនយ៉ាង។

១. ព្រះជាម្ចាស់ទ្រង់ឈប់សម្រាក នេះគឺជាថ្ងៃសម្រាក។

២. ព្រះជាម្ចាស់ទ្រង់ក៏ប្រទានពរដល់ថ្ងៃនេះ។ នៅថ្ងៃទីប្រាំទ្រង់ប្រទានពរដល់សត្វរស់រវើកនិងបក្សាបក្សី ហើយនៅថ្ងៃទីប្រាំមួយ ព្រះអង្គទ្រង់ប្រទានពរដល់មនុស្ស ប៉ុន្តែគ្មានកន្លែងណាពីថ្ងៃទីមួយដល់ថ្ងៃទីប្រាំមួយដែលនិទានថា ព្រះជាម្ចាស់បានប្រទានពរដល់ថ្ងៃ។ ដូច្នេះនេះបង្ហាញថា ថ្ងៃទីប្រាំពីរគឺជា*ពេលវេលាដែលពោរពេញដោយព្រះពរ*។

៣. ព្រះជាម្ចាស់ទ្រង់បានញែកថ្ងៃនេះទុកជាបរិសុទ្ធ ដូច្នេះនេះបង្ហាញថា ថ្ងៃទីប្រាំពីរគឺជា*ពេលវេលាដ៏បរិសុទ្ធ។*

៤. រាល់ថ្ងៃពីទីមួយដល់ថ្ងៃទីប្រាំមួយមានល្ងាចមានព្រឹកឡើង ប៉ុន្តែថ្ងៃទីប្រាំពីរឥតមានពាក្យនេះ ដូច្នេះហាក់ដូចជាថ្ងៃនេះមិនចប់ទេ គ្មានថ្ងៃទីប្រាំបីហើយយើងក៏មិនត្រឡប់ទៅថ្ងៃទីមួយវិញដែរ។ ដូច្នេះ **ថ្ងៃទីប្រាំពីរតំណាង*ពេលវេលាដ៏បរិសុទ្ធដែលពោរពេញដោយព្រះពរហើយស្ថិតស្ថេរអស់កល្បជានិច្ច*។**

តើហេតុអ្វីបានជាព្រះជាម្ចាស់បានបញ្ចប់នៅថ្ងៃទីប្រាំពីរ? តើហេតុអ្វីបានជាព្រះអង្គមិនបន្តទៅថ្ងៃទីប្រាំបី? និទានកថាបានបញ្ចប់នៅទីនេះពីព្រោះថ្ងៃទីប្រាំពីរគឺជាទីបញ្ចប់ ហើយជាគោលបំណងនៃការបង្កើតរបស់សព្វសារពើ។ នាពេលមានការរត់ប្រណាំង អ្នកប្រកួតរត់រហូតមកដល់ខ្សែជ័យ ប៉ុន្តែគេបញ្ចប់ការរត់បន្ទាប់ពីគេឆ្លងខ្សែជ័យ ពីព្រោះគេបានទៅដល់គោលដៅហើយ។



នោះជារូបភាពដែលយើងមាននៅក្នុងលោកុប្បត្តិ ២:១-៣។ ព្រះជាម្ចាស់ទ្រង់ក៏ឈប់សំរាកនៅថ្ងៃទីប្រាំមួយពីព្រោះថ្ងៃនេះគឺជាគោលបំណង។ ដូច្នេះនេះបង្រៀនថា ។ ប្រសិនបើនេះជាគោលបំណងរបស់ព្រះជាម្ចាស់ ដូច្នេះនេះក៏ជាគោលបំណងក្នុងជីវិតរបស់យើងផងដែរ។ បើមនុស្សមានគោលបំណងក្នុងជីវិតដែលខុសគ្នានឹងគោលបំណងរបស់ព្រះអាទិករ នោះគឺជាភាពល្ងង់។

ប៉ុន្តែ បើសិនជាយើងពិនិត្យមើលលោកីយ៍បច្ចុប្បន្នកាល យើងឃើញថាយើង*មិនរស់*នៅក្នុងពេលវេលាដ៏បរិសុទ្ធដែលពោរពេញដោយព្រះពរនោះទេ ប៉ុន្តែនៅសម័យពុករលួយដែលមានបញ្ហានិងសេចក្តីទុក្ខលំបាកជាច្រើន។ តើនេះបានកើតឡើងដោយរបៀបណា ? អត្ថបទបន្ទាប់ពីថ្ងៃទីប្រាំពីរ គឺនិទានកថាសួនច្បារអេដែនបានផ្តល់ចម្លើយសំរាប់សំនួរនោះ។ ចម្លើយខ្លីគឺ មនុស្សបានបះបោរជំទាស់នឹងព្រះអង្គ ហើយយើងខាតបង់សេចក្តីសម្រាកនេះ ដែលជាពេលវេលាដ៏បរិសុទ្ធដែលពោរពេញដោយព្រះពរនេះ។

## ស្តារគោលបំណងឡើងធ្វើជាថ្មី

ព្រះគម្ពីរទាំងមូលបាននិទានអំពីផែនការរបស់ព្រះជាម្ចាស់ដើម្បីនឹងស្តារគោលបំណងសំរាប់របស់សព្វសារពើ(គឺសេចក្តីសម្រាក)ជាថ្មីឡើងវិញ។ ព្រះអង្គបានជ្រើសរើសពួកអ៊ីស្រាអែលទៅជាប្រជារាស្ត្រដែលជាចំណែកមត៌ករបស់ទ្រង់ ហើយបានសន្យាថាទ្រង់នឹងប្រទានស្រុកមួយហើយស្រុកនោះគឺជា«សេចក្តីសំរាក» (ចោទិយកថា ១២:៩; យ៉ូស្វេ ១:១៣) គឺជាកន្លែងដែលព្រះអង្គនឹងប្រទានពរដល់ពួកអ៊ីស្រាអែលហើយជាទីកន្លែងបរិសុទ្ធរបស់ព្រះអង្គ។ ប្រជារាស្ត្ររបស់ព្រះអង្គបានទទួលសេចក្តីសម្រាក។

## បរាជ័យម្តងទៀត

ទោះយ៉ាងណាក៏ដោយ ព្រះជាម្ចាស់បានប្រកាសថា ជនជាតិអ៊ីស្រាអែលខ្លះនឹងមិនដែលចូលមកក្នុងសេចក្តីសំរាករបស់ព្រះអង្គឡើយពីព្រោះគេទាស់ទទឹងនឹងសេចក្តីបង្គាប់របស់ព្រះជាម្ចាស់ (ទំនុកដំកើង ៩៥:៨-១១)។

## ការអនុវត្តនៅក្នុងសញ្ញាថ្មី

អ្នកនិពន្ធនៃកណ្ឌហេព្រើរបានប្រើផ្ទៃរឿងនេះប្រយោជន៍ដើម្បីអប់រំគ្រីស្ទបរិស័ទ។ នៅហេព្រើរ ៣:៧-៤:១១ គាត់បានដកស្រង់ពីទំនុកដំកើង ៩៥ យ៉ាងហោចណាស់បួនដង ហើយបានដកស្រង់ លោកុប្បត្តិ ២:២ អំពីថ្ងៃទីប្រាំពីរយកមកអនុវត្តន៍ចំពោះគ្រីស្ទបរិស័ទ។ ការអនុវត្តនៅក្នុងអត្ថបទនេះគឺថា យើងដែលបានជឿលើដំណឹងល្អនៃព្រះគ្រីស្ទបានចូលសេចក្តីសម្រាកនោះហើយ (៤:៣) ហើយយើងត្រូវបន្តជឿលើព្រះគ្រីស្ទហើយបង្ហាញជំនឿនោះដោយយើងស្តាប់តាមដំណឹងល្អរបស់ព្រះគ្រីស្ទប្រយោជន៍ឲ្យយើងនឹងចូលសេចក្តីសម្រាកចុងក្រោយដែលយើងនឹងទទួលនៅថ្ងៃដែលព្រះគ្រីស្ទយាងមកវិញ (ហេព្រើរ ៤:៩-១១; ១១:១-១២:៣)។

លោកុប្បត្តិ ២:១-៣ → ចោទិយកថា ១២:៩ → ទំនុកដំកើង ៩៥:៨-១១ → ហេព្រើរ ៣:៧-៤:១១ → វិវរណៈ ២១-២២

បើអញ្ចឹង តើការអនុវត្តនៃ លោកុប្បត្តិ ២:១-៣ សំរាប់គ្រីស្ទបរិស័ទបច្ចុប្បន្ននេះគឺជាអ្វី? ចម្លើយគឺ ជឿនិងប្រកាសដំណឹងល្អនៃព្រះគ្រីស្ទ។ បើយើងយល់ លោកុប្បត្តិ ២:១-៣ នៅក្នុងបរិបទនៃរឿងតែមួយនៅក្នុងព្រះគម្ពីរទាំងមូល នោះយើងបានយល់ថា បើយើងបង្រៀននិងអនុវត្តន៍ លោកុប្បត្តិ ២:១-៣ យើងត្រូវប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ទ។ អ្នកខ្លះប្រឆាំងតបទៅនឹងការកាត់ស្រាយនេះហើយថា ទស្សនៈនេះបានសង្កត់ធ្ងន់ទៅលើព្រះគ្រីស្ទខ្លាំងពេក ប៉ុន្តែយើងបានឃើញហើយនៅខាងលើថា នេះជាមធ្យោបាយយ៉ាងពិតប្រាកដរបស់អ្នកនិពន្ធនៅក្នុងសញ្ញាថ្មីក្នុងការអនុវត្ត លោកុប្បត្តិ ២:១-៣។




មេរៀននេះជាតែឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ច្រើនទៀតដែលបញ្ជាក់ថា **របៀបដែលសញ្ញាចាស់បានទាក់ទងនឹងយើងបច្ចុប្បន្នកាលគឺតាមរយៈព្រះគ្រីស្ទ។** នេះជាមធ្យោបាយរបស់អ្នកនិពន្ធនៅក្នុងសញ្ញាថ្មី។ មេរៀនក្រោយនឹងផ្តល់ឧទាហរណ៍បន្ថែមទៀត។

